# **ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
# **អភិបូជាអធិដ្ឋានពេញមួយយប់នៅកំពង់សោម**
# **ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧**

អត្ថបទទី១៖រម ៨,២៨-៣០
ដំណឹងល្អ៖មថ ១,១-២៣

បងប្អូនជាទីស្រឡាញ់!

មាន បងប្អូនខ្លះ បានទៅប្រទេសឥណ្ឌូនេស៊ីដើម្បីចូលរួមជាមួយទិវាយុវជនអាស៊ី។ នៅភូមិភាគនោះ មានគ្រីស្តបរិស័ទដប់ម៉ឺននាក់ ជាភូមិភាគមួយពិសេសនៅក្នុងប្រទេសឥណ្ឌូនេស៊ី និងនៅក្នុងប្រទេសម៉ាឡេស៊ី ប្រទេសនៅជុំវិញឥណ្ឌូនេស៊ីទាំងអស់ ដោយសារមាននិស្សិតទេវវិទ្យាល័យច្រើនមែនទែន គឺ មានមួយរយកៅសិបនាក់។ រាល់ឆ្នាំ គេមានប្រាំ ប្រាំមួយ ប្រាំពីរនាក់ ដែលតែងតាំងជាបូជាចារ្យ។ ប្រសិនបើយើងប្រៀបធៀបនឹងយើង ដប់ម៉ឺននាក់មានមួយរយកៅសិបនាក់ យើងមានពីរម៉ឺននាក់ ត្រូវការមានច្រើនដែរ។ ពេល បងស្រីដុនបូស្កូសាឡេស៊ាន មកដល់បងស្រីសួរខ្ញុំថា "តើថ្ងៃនេះមានស្រីៗច្រើនឬអត់?" ក្រោយមកខ្ញុំប្រាប់បងស្រីជេត "បងស្រីសូមញញឹមស្អាតទៅ ដើម្បីឲ្យស្រីៗចាប់អារម្មណ៍អំពីបងស្រី"។ ប៉ុន្តែតាមពិត ខ្ញុំនិយាយដូចនេះ ដោយសារចំនួនមនុស្សមិនសំខាន់ទេ ប៉ុន្តែអ្វីដែលសំខាន់បំផុតគឺសម្រាប់យើងដែលជាយុវជន យុវនារី ដែលយល់ថាព្រះជាម្ចាស់ស្រឡាញ់យើងតាំងពីដើមរៀងមក ដូចយើងបានស្តាប់ព្រឹកមិញ។ នៅថ្ងៃនេះ យើងបានស្តាប់អត្ថបទទីមួយដែលថា "**បងប្អូនជាទីស្រឡាញ់! យើងដឹងថាអ្វីៗទាំងអស់សូមភ្ជាក់ឡើងដើម្បីឲ្យអស់អ្នកដែលស្រឡាញ់ព្រះជាម្ចាស់ទទួលផលល្អ គឺអ្នកដែលព្រះអង្គបានត្រាស់ហៅមកស្របតាមគម្រោងការរបស់ព្រះអង្គ ត្បិតអស់អ្នកដែលព្រះអង្គបានជ្រើសរើសទ្រង់ក៏បានតម្រង់គេទុកជាមុនឲ្យមានលក្ខណៈដូចព្រះបុត្រារបស់ព្រះអង្គដែរ** អរគុណព្រះជាម្ចាស់! ថ្ងៃនេះជាព្រះបន្ទូលសម្រាប់យើងមែនទែន! ប្រសិនបើខ្ញុំសួរបងប្អូនបានស្រឡាញ់ព្រះជាម្ចាស់ឬអត់? យើងឆ្លើយថាស្រឡាញ់ ដូច្នេះយើងនៅក្នុងចំណោមក្រុមនេះ "**អស់បងប្អូនដែលស្រឡាញ់ព្រះជាម្ចាស់ ព្រះជាម្ចាស់បានរៀបចំគម្រោងការទុកជាមុន** ដើម្បីណែនាំឲ្យយើងមានលក្ខណៈជាបុត្ររបស់ព្រះអង្គ ឲ្យយើងមានលក្ខណៈដូចព្រះបុត្រារបស់ព្រះអង្គដែរ។ ព្រឹកមិញ ខ្ញុំបាននិយាយថា យើងមានមហាកិត្តិយស ដោយសារយើងជាបុត្រាបុត្រីរបស់ព្រះបិតា។ ប៉ុន្តែយប់នេះ មហាកិត្តិយសដល់កំពូល! គឺយើងមានលក្ខណៈដូចព្រះ

បុត្រារបស់ព្រះអង្គ មិនមែនតែជាបុត្រធីតារបស់ព្រះជាម្ចាស់ទេ ប៉ុន្តែយើងមានលក្ខណៈដូចព្រះបុត្រារបស់ព្រះអង្គ ដោយទទួលព្រះយេស៊ូដែលជាបងរបស់យើង ប៉ុន្តែដោយដឹងថាព្រះជាម្ចាស់បានរៀបចំឲ្យយើងមានលក្ខណៈដូចព្រះបុត្រា។ លក្ខណៈដូចព្រះបុត្រា មានន័យថាព្រះជាម្ចាស់ស្រឡាញ់យើង និងព្រះជាម្ចាស់ណែនាំយើងឲ្យមានសមត្ថភាពពេញលក្ខណៈដើម្បីរស់នៅក្នុងសង្គមបច្ចុប្បន្ននេះ ដើម្បីផ្តល់សក្ខីភាពដូចព្រះយេស៊ូពីដើម។ យើងមានលក្ខណៈដូចព្រះបុត្រា! ដូច្នេះយើងលែងភ័យអស់ហើយ ដោយសារព្រះជាម្ចាស់បានជ្រើសរើសយើង និងប្រទានអ្វីៗទាំងអស់ដែលយើងត្រូវការ។

នៅពេលព្រះនាងម៉ារីបានឆ្លើយ "**ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់** ព្រះនាងម៉ារីប្រហែលមិនដឹងអ្វីដែលគាត់កំពុងឆ្លើយ ដោយសារធ្វើជាម្តាយរបស់ព្រះជាម្ចាស់មិនធម្មតាទេ។ ពេលព្រះនាងម៉ារីបានចាប់ផ្តើមមានផ្ទៃពោះល្មម លោកយ៉ូសែប គាត់មិនសប្បាយចិត្តទេ!។ លោកយ៉ូសែប គាត់ជាមនុស្សសុចរិតគាត់បានសម្រេចចិត្ត "ខ្ញុំចោលនាងម៉ារីស្ងាត់ៗកុំឲ្យមានរឿងធំ ដោយសារតែនាងម៉ារីបានទៅលេងជាមួយប្រុសផ្សេងក្បត់ខ្ញុំអស់ហើយ"។ ប៉ុន្តែក្រោយមក ព្រះជាម្ចាស់បានបំភ្លឺលោកយ៉ូសែប ដូចយើងបានស្តាប់អម្បាញ់មិញ "**ព្រះនាងម៉ារីបានទៅជាមាតារបស់ព្រះអម្ចាស់ ដោយសារការអស្ចារ្យនៃព្រះវិញ្ញាណដ៏វិសុទ្ធ**។ ប៉ុន្តែនេះព្រះនាងម៉ារីមិនយល់ទេ នៅពេលឮថាធ្វើជាព្រះមាតារបស់ព្រះអង្គ គាត់មិនយល់អ្វីទេ ប៉ុន្តែគាត់ធ្វើ និងព្រះជាម្ចាស់ប្រទានសមត្ថភាពឲ្យគាត់ទៅមុខ នៅពេលដែលព្រះនាងម៉ារីបាននិយាយតែមួយម៉ាត់ "**នាងខ្ញុំឯកភាពធ្វើជាមាតារបស់ព្រះអង្គ ឲ្យធ្វើតាមការសម្រេចចិត្តរបស់ព្រះអង្គចុះ**" នៅពេលនោះព្រះនាងម៉ារីបានទទួលកម្លាំង បានទទួលសមត្ថភាពបានទទួលអ្វីៗទាំងអស់ដើម្បីទៅមុខ ព្រះជាម្ចាស់មិនចោលគាត់។

ដូច្នេះកុំខ្លាចអី! នៅពេលយើងឆ្លើយយើងទៅ ដូចយើងបានស្តាប់សាក្ខីភាពច្រើនថ្ងៃនេះ បងប្រុសដាម៉ូ លោកឪពុកលី លោកហ្វ្រង់ស្វ័រសីមេដាល ក៏និយាយដែរ។ យើងមានសំណួរច្រើន យើងមានការល្បួងច្រើន យើងមានការភ័យច្រើនដែរ។ ប៉ុន្តែនៅពេលដែលយើងថា "**បាទខ្ញុំទៅមុខ**" យើងដឹងថាចម្លើយរបស់យើង យើងមានកម្លាំងមួយយ៉ាងពិសេសដែលព្រះជាម្ចាស់ប្រទានឲ្យដើម្បីទៅមុខបាន ហើយយើងមានអំណរសប្បាយច្រើន។ យើងបានសួរសំណួរច្រើនទៅលោកឪពុក តើយើងមានទុក្ខលំបាកអ្វីខ្លះ? តើឧបស័គ្គអ្វីខ្លះ? តើមានការពិបាកអ្វីខ្លះ? ប៉ុន្តែឥឡូវនេះ ខ្ញុំអាចឆ្លើយ ថា លោកឪពុកលីនិងខ្ញុំមានអំណរ

សប្បាយច្រើន ខ្ញុំគិតថាប្រាំឆ្នាំដែលខ្ញុំជាមួយលោកឪពុកលីនៅកំពត ខ្ញុំទទួលអំណរសប្បាយជាងគេនៅក្នុងជីវិតខ្ញុំជាបូជាចារ្យដោយសារខ្ញុំទាំងពីរនាក់ យើងចាប់ផ្តើមព្រះសហគមន៍ដែលអត់មានអីសោះ នៅកំពតអត់មានគ្រីស្តបរិស័ទមានតែម្នាក់ ក្នុយលោកឪពុកលីនៅជាមួយយើង។ រាល់ពេលព្រឹកយើងសូត្រតាមកំណត់ ពេលល្ងាច ពេលយប់អភិបូជាជាមួយគ្នា ថ្ងៃច័ន្ទគាត់ទេសនា ថ្ងៃអង្គារខ្ញុំទេសនា ថ្ងៃពុធគាត់ទេសនា ថ្ងៃព្រហស្បត្ត៏ខ្ញុំទេសនា ថ្ងៃសុក្រគាត់ទេសនា...។ល។ ខ្ញុំរៀនទេសនាពីគាត់ច្រើនណាស់ ទេសនាឲ្យគ្នាទៅវិញទៅមកតែពីរនាក់។ ប៉ុន្តែនៅពេលនោះ យើងទទួលកម្លាំងកាយកម្លាំងចិត្ត ហើយខ្ញុំជឿថានេះជាមូលដ្ឋានគ្រឹះយ៉ាងពិសេស ហើយក្រោយមកយើងចែកកាលវិភាគរបស់យើងឆ្នាំទីមួយអត់សូវមានមនុស្ស តែក្រោយមកយើងមានមណ្ឌល មានយុវជនខ្លះៗ។ អាហារពេលព្រឹកខ្ញុំបណ្តេញលោកឪពុក ថាលោកឪពុកទៅផ្សារ កុំញ៉ាំអាហារពេលព្រឹកជាមួយខ្ញុំ ខ្ញុំចង់ឲ្យយើងប្រកាសដំណឹងល្អដែរ។ នៅពេលយើងទៅផ្សារញ៉ាំអាហារជាមួយគេ យើងមានឱកាសជួបជាមួយគេច្រើន។ អាហារពេលថ្ងៃត្រង់គាត់បណ្តេញខ្ញុំ ដូច្នេះខ្ញុំទៅផ្សារនិងជួបគេច្រើនណាស់ តែនៅពេលយប់ញ៉ាំជាមួយគ្នា និងជាមួយក្រុមសិស្ស។ ដើម្បីបង្កើតមិត្តភាព បង្កើតសន្តិភាព និងជីវិតជាព្រះសហគមន៍ ខ្ញុំគិតថាយើងបានទទួលកម្លាំងច្រើន បានទទួលអំណរសប្បាយច្រើន ដោយលើកទឹកចិត្តគ្នា អធិដ្ឋានជាមួយគ្នា។ ជីវិតរបស់យើងពោរពេញទៅដោយអំណរសប្បាយ នៅពេលដែលយើងទទួលគម្រោងការរបស់ព្រះជាម្ចាស់ **ព្រះជាម្ចាស់ចង់បានអ្វីពីខ្ញុំ ខ្ញុំធ្វើតាម**។ ពេលនោះយើងឃើញយ៉ាងច្បាស់ ទ្រង់បានត្រាស់ហៅ ហើយអស់អ្នកដែលទ្រង់បានត្រាស់ហៅនេះ ទ្រង់ក៏បានប្រោសឲ្យគេបានសុចរិត។ មនុស្សសុចរិតដល់កំពូលគឺព្រះយេស៊ូ និងមនុស្សសុចរិតមានខ្លះៗ លោកតាអាប្រាហាំ បុព្វបុរសរបស់យើង លោកយ៉ូសែប លោកយ៉ូហានបាទីស្ត យើងមានប៉ុន្មាននាក់នៅក្នុងគម្ពីរគេថាជាមនុស្សសុចរិត។ យើងជា យើងមានលក្ខណៈដូចព្រះបុត្រា និងព្រះជាម្ចាស់ណែនាំឲ្យយើងជាមនុស្សសុចរិត។ មនុស្សសុចរិត មានន័យថាជាមនុស្សដែលដើរតាមផ្លូវត្រឹមត្រូវ អស់ពីសមត្ថភាពនៅក្នុងសេចក្តីស្រឡាញ់ ដើម្បីបង្កើតគម្រោងការនៅក្នុងជីវិតរបស់យើង និងដើម្បីណែនាំឲ្យបងប្អូនឯទៀតៗមានសេចក្តីសុខសាន្ត។

និងផ្លែផលដ៏ល្អដែលព្រះជាម្ចាស់បាននិយាយ ដើម្បីឲ្យអ្នកស្រឡាញ់ព្រះជាម្ចាស់ទទួលផលល្អ ផលល្អដល់កំពូល ពេលយើងជាមនុស្សសុចរិតហើយទ្រង់ក៏ប្រទានសិរី

រុងរឿងដូចព្រះយេស៊ូតែម្តង នៅពេលដែលព្រះយេស៊ូឡើងលើភ្នំតាប៉ប់ និងព្រះយេស៊ូប្រែជាពណ៌ស និងរស្មីរបស់ព្រះយេស៊ូជាសិរីរុងរឿង ដែល ណែនាំឲ្យយើងទាំងអស់គ្នា។ ដូចលោក ប្រាង់ស្វ័រអេមេដាល ថាគោលដៅរបស់យើងទៅជាសន្តសន្តិ គោលដៅរបស់យើងទៅជាមនុស្សដ៏វិសុទ្ធ ដែលជាប់ជាមួយព្រះជាម្ចាស់យ៉ាងជិតស្និទ្ធបំផុត និងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ នៅពេលនោះខ្ញុំឃើញលោកឪពុក ខ្ញុំឃើញបងប្អូនទាំងអស់ ខ្ញុំឃើញបងប្រុសបងស្រីទាំងអស់ដែលកំពុងអង្គុយ ខ្ញុំចាប់ផ្តើមមើលពន្លឺដ៏ពិសេស ពន្លឺនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដែលកំពុងចេញពីភ្នែកពីបេះដូងរបស់យើង ក៏ប៉ុន្តែអត់ទាន់ដល់កំពូលទេ ដូច្នេះ យើងត្រូវការបន្តថែមទៀត។ យប់នេះ ពេលយើងចេញពីអធិដ្ឋាននេះ ឲ្យយើងទៅមើលសមុទ្រ យើងឃើញពន្លឺច្រើនដែលកំពុងភ្លឺ ឲ្យយើងនឹកឃើញ "ខ្ញុំជាពន្លឺមួយដូចនេះដើម្បីបំភ្លឺពិភពលោក" ហើយខ្ញុំភ្លឺដោយសារ ខ្ញុំជាមនុស្សសុចរិត ដោយសារខ្ញុំជាមនុស្សប្រកបដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់។ សិរីរុងរឿងរបស់ព្រះជាម្ចាស់ពិសេស ហើយខ្ញុំយល់ថានៅក្នុងភាពងងឹតនៃពិភពលោករបស់យើង ខ្ញុំជាពន្លឺតូចនេះ។ យើងជាមនុស្សមិនអស្ចារ្យមិនមែនពិសេស ប៉ុន្តែយើងពេញដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់ដើម្បីឲ្យសិរីរុងរឿងនេះភ្លឺដល់បងប្អូនឯទៀតៗ។ ប៉ុន្តែដើម្បីឲ្យភ្លឺ គិតពិចារណាយប់នេះ ខ្ញុំធ្វើអ្វីខ្លះបាន? ខ្ញុំធ្វើយ៉ាងម៉េចបាន? ខ្ញុំធ្វើយ៉ាងម៉េចដើម្បីឲ្យព្រះជាម្ចាស់មានសេចក្តីសុខដោយសារខ្ញុំ? ទោះបីព្រះជាម្ចាស់ពោរពេញទៅដោយសេចក្តីសុខសាន្ត ទោះបីព្រះជាម្ចាស់ជាមនុស្សសុចរិត និងទោះបីជាព្រះសុចរិត និងដ៏វិសុទ្ធអស់កល្បជានិច្ច យើងណែនាំឲ្យព្រះជាម្ចាស់មានសេចក្តីសុខដែរ។ នៅពេលយើងឆ្លើយតប ខ្ញុំសុខចិត្តទៅ ខ្ញុំចង់ធ្វើនេះ ដើម្បីឲ្យទេពកោសល្យរបស់ខ្ញុំមានផ្លែយ៉ាងច្រើន និងដើម្បីណែនាំឲ្យមនុស្សដទៃមានសេចក្តីសុខច្រើន មានសេចក្តីសង្ឃឹមច្រើន និងមានអនាគតល្អដោយសារខ្ញុំ។

ដូច្នេះពេលយើងទៅវិញ យើងនឹកឃើញយើងទៅឆ្ងាយពីសមុទ្រ ប៉ុន្តែនៅក្នុងភូមិយើង នៅក្នុងទីក្រុងរបស់យើង ឲ្យយើងយល់ថាយើងជាពន្លឺនេះដែលបង្ហាញអំពីសិរីរុងរឿងរបស់ព្រះជាម្ចាស់ នេះណែនាំឲ្យយើងមានសេចក្តីសុខសាន្ត។ យើងអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានព្រះនាងម៉ារី អត់មានព្រះនាងម៉ារី អត់មានព្រះយេស៊ូ។ សូមយល់ថា អត់មានខ្ញុំដែលឈ្មោះសម្បត្តិ អត់មានខ្ញុំដែលឈ្មោះបូរី អត់ខ្ញុំដែលឈ្មោះលី អត់មានខ្ញុំដែលឈ្មោះលីហៀង អត់មានខ្ញុំដែលឈ្មោះសុភាព រស្មីខ្វះដើម្បីឲ្យសិរីរុងរឿងរបស់

ព្រះជាម្ចាស់ភ្លឺគ្រប់ទីកន្លែង។ ដូច្នេះកុំឲ្យខ្វះ ឲ្យយើងទាំងអស់គ្នាភ្ញាក់ស្មារតីដោយយល់ថា សមត្ថភាពខ្ញុំតែប៉ុណ្ណឹង ប៉ុន្តែព្រះអង្គប្រទានទាំងអស់ឲ្យខ្ញុំទទួល។ ដូច្នេះឧបសគ្គមាន ប៉ុន្តែ ឧបសគ្គយើងឈ្នះ ដោយសារព្រះជាម្ចាស់គង់នៅ។

អរព្រះគុណព្រះជាម្ចាស់ យើងនៅស្ងៀមស្ងាត់ដោយនឹកឃើញដល់ជីវិតរបស់យើង ម្ដងទៀត ដោយសូមព្រះអង្គឲ្យជីវិតយើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីធ្វើជា យុវជន យុវនារី យ៉ាងពិសេសអស្ចារ្យ នៅក្នុងសង្គមរបស់យើង ធ្វើ ជាពន្លឺយ៉ាងតូចមួយ ដែលបង្ហាញអំពីសេចក្តីស្រឡាញ់ និងសិរីរុងរឿងដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ អាម៉ែន៕